**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងអប់រំ យុវជន និងកីឡា**

**លេខ: ៧២ អយក.សណន**

# សេចក្តីណែនាំស្តីពី ការពន្យារពេលនៃការចូលរៀនឡើងវិញ សម្រាប់គ្រឹះស្ថានសិក្សាគ្រប់កម្រិត គ្រប់ប្រភេទ ទាំងសាធារណៈនិងឯកជន និង គ្រឹះស្ថានបណ្តុះបណ្តាលគ្រូ នៅទូទាំងប្រទេស

ផ្អែកតាមរបាយការណ៍ស្ថានភាពរាតត្បាតនៃជំងឺកូវីដ១៩ របស់ក្រសួងសុខាភិបាល ដែលតម្រូវឱ្យបន្តអនុវត្តវិធានការបង្ការ និងទប់ស្កាត់ការរីករាលដាល និងតាមការណែនាំរបស់រាជរដ្ឋាភិបាលកម្ពុជា ក្រសួងអប់រំ យុវជន និងកីឡាសូមណែនាំដល់គ្រឹះស្ថានសិក្សាគ្រប់កម្រិត គ្រប់ប្រភេទ ទាំងសាធារណៈនិងឯកជននៅទូទាំងប្រទេស ដូចតទៅ៖

**១. គ្រឹះស្ថានសិក្សាចំណេះទូទៅសាធារណៈ (បឋមសិក្សា ដល់មធ្យមសិក្សាទុតិយភូមិ) និងមត្តេយ្យសិក្សា**

- ពន្យារពេលនៃការចូលរៀនឡើងវិញ រហូតដល់មានការជូនដំណឹងជាថ្មី
- ផ្សព្វផ្សាយនិងសហការល្អជាមួយមាតាបិតា អ្នកអាណាព្យាបាលសិស្ស អាជ្ញាធរដែនដី ដើម្បីជំរុញគាំទ្រ ដល់ការសិក្សាពីចម្ងាយ និងការសិក្សាតាមប្រព័ន្ធអេឡិចត្រូនិក ដល់សិស្សានុសិស្សនៅតាមលំនៅដ្ឋាននិងសហគមន៍ តាមមធ្យោបាយនិងលទ្ធភាពជាក់ស្តែង
- អនុវត្តការសម្អាតបរិវេណគ្រឹះស្ថានសិក្សាជាប្រចាំ
- ត្រូវរៀបចំវេនយាមប្រចាំការ ដើម្បីធានាសុវត្ថិភាព និងសន្តិសុខ
- លើកទឹកចិត្តឲ្យសិស្សខ្ចីសៀវភៅសិក្សាគោល ដើម្បីលើកកម្ពស់ស្វ័យសិក្សា និងសិក្សាពីចម្ងាយ។

**២. គ្រឹះស្ថានសិក្សាចំណេះទូទៅឯកជន (បឋមសិក្សា ដល់មធ្យមសិក្សាទុតិយភូមិ) និងមត្តេយ្យសិក្សា**

- ពន្យារពេលនៃការចូលរៀនឡើងវិញ រហូតដល់មានការជូនដំណឹងជាថ្មី
- បន្តអនុវត្តវិធានការ "ការសិក្សាពីចម្ងាយ និងការសិក្សាតាមប្រព័ន្ធអេឡិចត្រូនិក" ជាពិសេស សេចក្តីណែនាំលេខ ២១ អយក.សណន ចុះថ្ងៃទី ១៣ ខែមេសា ឆ្នាំ២០២០ ស្តីពី ការលើកកម្ពស់ការបង្រៀននិងរៀនពីចម្ងាយ ឬតាមប្រព័ន្ធអេឡិចត្រូនិក ដោយគ្រឹះស្ថានសិក្សាឯកជនគ្រប់កម្រិត
- អនុវត្តការសម្អាតបរិវេណគ្រឹះស្ថានសិក្សាជាប្រចាំ។

**៣. គ្រឹះស្ថានបណ្តុះបណ្តាលគ្រូ**

- ពន្យារពេលនៃការចូលរៀនឡើងវិញ រហូតដល់មានការជូនដំណឹងជាថ្មី
- ត្រៀមលក្ខណៈអនុវត្ត "ការសិក្សាពីចម្ងាយ និងការសិក្សាតាមប្រព័ន្ធអេឡិចត្រូនិក"
- អនុវត្តការសម្អាតបរិវេណគ្រឹះស្ថានសិក្សាជាប្រចាំ។

CS Scanned with CamScanner

អាសយដ្ឋានលេខ៨០ មហាវិថី ព្រះនរោត្តម ភ្នំពេញ កម្ពុជា ទូរស័ព្ទ: (៨៥៥-២៣) ២២០ ៦៧៣ / ២២០ ៣០៤ ទូរសារ: (៨៥៥-២៣) ២១៧ ២៥០ / ២១២ ៥១២
អ៊ីមែល: info@moeys.gov.kh / administration@moeys.gov.kh គេហទំព័រ: www.moeys.gov.kh

**៤. គ្រឹះស្ថានឧត្តមសិក្សាទាំងសាធារណៈនិងឯកជន**

- ពន្យារពេលនៃការចូលរៀនឡើងវិញ រហូតដល់មានការជូនដំណឹងជាថ្មី
- បន្តអនុវត្តផែនការ "ការសិក្សាពីចម្ងាយ និងការសិក្សាតាមប្រព័ន្ធអេឡិចត្រូនិក" ជាពិសេស សេចក្តីណែនាំលេខ ២១ អយក.សណន ចុះថ្ងៃទី ១៣ ខែមេសា ឆ្នាំ២០២០ ស្តីពី ការលើកកម្ពស់ការបង្រៀននិងរៀនពីចម្ងាយ ឬតាមប្រព័ន្ធអេឡិចត្រូនិក ដោយគ្រឹះស្ថានសិក្សាឯកជនគ្រប់កម្រិត
- រៀបចំ កែលម្អ និងអភិវឌ្ឍវេទិកាឌីជីថល សម្រាប់គ្រឹះស្ថានឧត្តមសិក្សា ដើម្បីផ្តល់សេវាអប់រំតាមប្រព័ន្ធអេឡិចត្រូនិក
- អនុវត្តការសម្អាតបរិវេណគ្រឹះស្ថានសិក្សា។

**៥. មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត**

- ផ្សព្វផ្សាយ និងជំរុញការសិក្សាពីចម្ងាយ និងការសិក្សាតាមប្រព័ន្ធអេឡិចត្រូនិកដល់គ្រប់ភាគីពាក់ព័ន្ធ
- បន្តតាមដាន និងរាយការណ៍ហេតុការណ៍ ដែលអាចកើតមានឡើងចំពោះបុគ្គលិកអប់រំ និងសិស្សានុសិស្ស និងផ្តល់ព័ត៌មានដល់ក្រសួងអប់រំ យុវជន និងកីឡារៀងរាល់ថ្ងៃ តាមប្រព័ន្ធទំនាក់ទំនងដែលមានស្រាប់ ក្នុងករណីមានការសង្ស័យណាមួយ
- ដោះស្រាយនូវសំណូមពររបស់ថ្នាក់មូលដ្ឋាន តាមសមត្ថភាព និងលទ្ធភាព។

**៦. មាតាបិតា អ្នកអាណាព្យាបាល**

- ក្រសួងសូមលើកទឹកចិត្តដល់មាតាបិតា អ្នកអាណាព្យាបាលសិស្សគ្រប់រូប ត្រូវបន្តជំរុញឱ្យកូនចៅធ្វើស្វ័យសិក្សានៅតាមផ្ទះ សិក្សាពីចម្ងាយឬតាមប្រព័ន្ធអេឡិចត្រូនិក និងត្រូវមើលថែកូនចៅអនុវត្តផែនអនាម័យ និងចៀសវាងទៅកន្លែងមួយចំនួនដែលប្រឈមនឹងការឆ្លងខ្ពស់។

ទទួលបានសេចក្តីណែនាំនេះ មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត ត្រូវផ្សព្វផ្សាយឱ្យបានទូលំទូលាយដល់គ្រប់ការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ កម្រងសាលារៀន សាលារៀន និងគ្រឹះស្ថានបណ្តុះបណ្តាលគ្រូគ្រប់កម្រិត។ ដោយឡែក គណៈគ្រប់គ្រងសាលារៀនគ្រប់កម្រិត គ្រឹះស្ថានបណ្តុះបណ្តាលគ្រូ និងគ្រឹះស្ថានឧត្តមសិក្សាទាំងអស់ បុគ្គលិកអប់រំ មាតាបិតា អ្នកអាណាព្យាបាលសិស្សគ្រប់រូប សូមចូលរួមសហការអនុវត្តដោយស្មារតីទទួលខុសត្រូវខ្ពស់ និងសូមមេត្តាតាមដានជាប្រចាំនូវការផ្សព្វផ្សាយរបស់ក្រសួងអប់រំ យុវជន និងកីឡា និងក្រសួងសុខាភិបាល។/

ថ្ងៃ សុក្រ ១០រោច ខែចេត្រ ឆ្នាំជូត ទោស័ក ព.ស.២៥៦៣

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែមេសា ឆ្នាំ ២០២០

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

បណ្ឌិតសភាចារ្យ **ហង់ជួន ណារ៉ុន**

**កន្លែងទទួល៖**

- គ្រប់សាលារាជធានី ខេត្ត
- គ្រប់អគ្គនាយកដ្ឋាន និងអគ្គាធិការដ្ឋាន
- ខុទ្ទកាល័យឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រី
  **"ដើម្បីជ្រាបជាព័ត៌មាន"**
- គ្រប់មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត
  **"ដើម្បីអនុវត្ត"**
- កាលប្បវត្តិ
- ឯកសារ នាយកដ្ឋានរដ្ឋបាល

CS Scanned with CamScanner